Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 1/1 (July 2000): 24–31

# Wholistic Ministry and Mission

*Graham CHIPPS*

Wholism and wholistic ministry (including mission) are about being servants of others—being concerned for the whole person and the whole of the context in which he or she lives. Each one of the following is true for every person in every country:

- Each person is created in the image of God, but each one has become self-serving and rebellious through a heart of sin. Each person is a sinner who has also been sinned against.
- Each person is a system of physical, intellectual, relational and social, spiritual, psychological and emotional, moral, volitional, and cultural dimensions. Each part of the system significantly influences all the others.
- Each person lives within a context of culture, family, politics, spiritual forces, society and nation, environment, economics, art, entertainment, law and education.
- Each person is designed to be in relationship with God and each is dysfunctional in everything whenever this relationship is weak or non-existent.
- Each person is condemned to eternal death by their sin, unless by God's grace she or he is joined to Jesus Christ through faith.

Wholistic ministry recognizes the importance of addressing all these areas of life if the well-being of persons and nations is to be increased beyond the superficial. Our understanding of what is and is not in the interests of this well-

being is determined by what God says is right and good in the Bible.

However, different reasons are given by people as to why wholistic ministry is good. There are three different approaches. The first is unethical, the second is good but limited, and the third is best because its focus is Christ and His supremacy rather than on the needs of people. These approaches are:

1) **Wholistic ministry as a means to an end.** Wholistic ministry has no value in and of itself except as a way to get easier access to people to then evangelize them. This is the motivation which sees everything else as just a way of influencing people to listen to the Gospel. This reason is deceitful, manipulative, unacceptable, contrary to Scripture and dishonouring to God.
2) **Wholistic ministry as an expression of love and a longing for justice and goodness in all of life.** Wholistic ministry is motivated by a desire to care for people. It addresses their needs and all the issues of life so that their well-being is increased, and they are less burdened by the failings of individuals and societies. This reason is good and Biblical, but it leaves out the more important motivations which focus on God's purposes as noted in approach 3) below.

   An example of this is the exhortation to do "good works." This expression in the first century emphasized the value of contributing to the local community. It could be as small as helping out a neighbour, or something much larger such as emergency relief or a development project which benefits the whole community.
3) **Wholistic ministry as a submission to the reign of Christ.** Wholistic ministry follows the recognition that as God's servants, we are called to seek after His will in all things as He works in the world. God is working out His purposes through the rule of His Son Jesus and His purposes involve the wholistic transformation of all creation (except for what He removes through judgment).

This reason is the strongest motivation because it starts and ends in God's will in Christ. The following points describe this wholistic work of God.

## The Very First Wholistic Ministry.

God has always been wholistic in His work. His creation includes all the ingredients of life noted above—except sin and its consequences. He created all things: the visible and the invisible, the personal and the impersonal, the material and the spiritual, each individual human being and the society in which he or she lives, the earthly and the heavenly, the psychological and the intellectual, the lowly things and the rulers and authorities. He created male and female, sky and sea, plants and animals in multiple species, wind and water, rocks and clouds. His creation is a living, breathing, changing work of art. This creative work of great beauty was perfect every moment of every day, and yet every moment it changed without losing any of its perfection. And God declared it to be very good (Genesis 1:31).

Since then, human sin and Satanic pollution have done all they could, but despite the damage they have done and the curse of God in judgment (Genesis 3), this creation still retains much of the goodness God created. The creation reflects God's glory and speaks to us of His character and power (e.g. Psalms 8, 19, 104, 148).

We need to appreciate how much the creation continues to bring God pleasure and how much He grieves when His work of art is treated with contempt. The human race has been given management responsibility for the creation and we have not done this at all well. When we disregard our responsibility to manage well all He has made, we have adopted an attitude in which God Himself is not respected.

## Sin, Society and Creation.

In Genesis 3–11, we read of the consequences of human sin. All of life was and still is affected—even the earth itself.

Human society grows in pride, evil, and corruption, and God's judgments then included a massive flood and the scattering people into different languages. Even brothers turned against brothers in murder.

The relationship between sin and the whole of creation is strongly expressed in the cursing of the ground and the major change in relationships and work when God's judgment came in Genesis 3:17–19. Likewise, Paul describes the liberation of the whole creation from the curse and decay of sin as being directly associated with the liberation from sin which God brings to His children. God is being quite wholistic in all this.

Furthermore we often read in the Mosaic Law, in the Psalms and in the Prophets of God's passion for the victims of sin: the poor, orphans, widows, the oppressed, the prisoners, refugees. Sin inevitably involves idolatry, injustice, greed, and immorality; as a result, many individuals are traumatized and nations become places of cruelty and violence. All of the consequences of individual and corporate sin are His concern. The whole of each person, the whole of every society and the whole of creation have all fallen short of perfectly displaying the glory of God. God's heart and mind often are described as deeply grieved by sin and all its consequences. God's passion and compassion are perfectly wholistic—as are His promises as to what He will do about His polluted and broken world.

## The Promises of God.

Even on the day on which the curse of judgment was first declared, God indicated that His promise was to overthrow the realm of evil. The child of the woman will crush the head of Satan (Genesis 3:15). To Abraham God promised blessing to all the nations of the earth. The law of Moses reflects the ideals of Godly society—holiness, compassion, and justice, with particular concern for the weak and vulnerable. All things in such a society are in harmonious relationship with all else (including the earth itself) in so far as all things are in harmonious relationship with God. This

law gives us much insight into the kind of society which will bring the blessing to all nations promised to Abraham.

The most central dimension to these promises of God is the promise of a Shepherd-King who is a descendent of King David and who is also Son of God (Psalm 2) and Son of Man (Daniel 7:9–14). He is Messiah, and it is through His rule over all nations that God will fulfill every promise. The prophets repeatedly speak of this Messiah (e.g., Isaiah 9:6–7, 11:1–5, 32:1–5, 42:1–7, 52–53, 61:1–9, Jeremiah 23:5–6, 33:15–16, Ezekiel 34:20–31, 37:24–28, Amos 9:11–15.) He will be the servant of God who will be the atoning sacrifice for sin (Isaiah 53).

Ezekiel and Jeremiah promise that God will purify and soften the human heart so that people incline towards God rather than against Him. Isaiah, Joel, and Ezekiel declare that God's Holy Spirit will be poured out to bring transformation—healing, purification, renewal. Isaiah emphasizes justice, peace, and righteousness for all the nations of earth. Several promise God's forgiveness. Those most victimized by sin will find God's freedom from poverty and oppression. Nations will cease to war against each other. Even amongst animals there will be harmony.

In short, the promise of God is to address the whole of life and bring changes to all things such that everything in heaven and earth is fully in accordance with His will. The Kingdom promised is global, wholistic and complete in every way. The inheritance promised to all who have faith as Abraham had faith is the whole earth fully transformed in accordance with God's Kingdom rule in Christ.

## The Coming of Messiah.

When Jesus commenced His ministry, He announced the beginnings of the rule of Messiah to fulfill God's promises. Regardless of how small the beginning, the work of God's Kingdom had begun. Jesus and the apostles are reported to have been constantly speaking of the Kingdom; it was central to their Gospel. Through the essential moments of His life, Jesus inaugurates the promised Kingdom. Birth and baptism, servant

ministry, suffering and death, resurrection and ascension, and finally Pentecostal pouring out: each one in some way plays a part in the beginnings of Christ's rule—with the cross being the pivotal event. In the cross, Jesus establishes His credentials to be confirmed as the supreme ruler over every nation and even over Satan, the archenemy of God. Furthermore, in the cross Jesus satisfies the Father's requirement of justice for sin by dying on behalf of sinners. God's forgiveness is for all who believe and through this faith the Kingdom promises begin to be experienced.

Nowhere in the New Testament do Jesus or the apostles challenge the wholistic nature of what the Messiah has come to do. Indeed, Jesus clearly demonstrates a concern for the whole person and the whole of the context in which each one lives. The only qualification is in size; there is no reduction in the agenda of the Messiah. Jesus says that the Kingdom has commenced very small but it will grow, and as it does it will impact upon more and more of the whole of life. How far it will develop before He returns to complete the work is never specified. The parable of the Wheat and the Weeds indicates that the world of evil will continue to grow even as the Kingdom grows.

In his first coming Jesus commenced His Kingdom reign in the smallest and humblest of ways. When He returns He will come with such majesty and glory and power that not one person will have any doubt as to who He is. At this time the work will be completed. The whole earth, the whole of every nation and society, the whole of the people of God, will be transformed into God's wholistic perfection.

It is important that we not forget that one of the necessary things for the fulfillment of God's promises is the judgment. The final judgment will be both punishment and cleansing. God will remove all persons who have chosen to follow other gods—themselves, idols, Satan, whatever. God will remove everything which is evil to the point of being beyond transformation. God will remove all the spiritual forces of evil from Satan himself to the lowliest of demons. This exclusion from everything that belongs to

God will be the most terrible of punishments: total absence of anything good.

## Some Important New Testament Statements.

In Ephesians, Paul writes strongly of the authoritative and supreme rule of Jesus over all other powers (1:20–23). He also says that one of the blessings of the Kingdom, which we already have received, is the revelation from God as to His purpose in Christ. All things in heaven and earth will eventually be brought under the headship or rule of Christ. This rule has commenced; when the time comes that God has designated, Jesus headship will be totally complete. Not that it is a wholistic rule; it is over all things in heaven and earth.

In Philippians 2:9–11, Paul describes Jesus as exalted by God to the place of supreme power and authority. In accordance with the promise of Isaiah 45:22–24, all creatures in heaven, on earth and under the earth will bow down to Jesus in acknowledgment of His Lordship. This is the purpose that God is working out in Christ.

Colossians 1:15–20 is a fascinating passage. Having stated that literally all that exists has been created by God in Christ, Paul speaks of reconciliation through the cross. The description of "all things" in verse 16–17 is wholistic in every way. And it is this wholistic collection of "all things" that are included in the reconciling work of God through Jesus. God is pleased to be wholistic! God's peace is wholistic! God's peace is the harmony of "all things" reconciled to Himself such that His relationship with "all things" is perfect. And when "all things" are reconciled to Himself, then "all things" can experience harmony with all other things.

Romans 8:19–21 likewise reflects the wholistic nature of God's work of liberation.

The central focus in any Christian understanding of wholism is the sovereignty of Jesus Christ. He alone is Lord and Messiah. He alone rules supremely over the whole creation. His will is to be implemented is every sphere of life. His Lordship

over all things to bring the changes promised by God is the point at which we begin to understand the wholistic nature of our work as His servants.

## How Then Shall We Serve?

We are to be servants of Christ before anything else. His rule is the basis for determining our ministry. His wholistic Kingdom agenda is ours. We are called to follow Him in the mission of wholistic transformation of all things. It is His work and He works through us.

Biblical wholistic ministry/mission has four components:

- **Word**—Gospel proclamation to call on all persons and nations to submit to Christ the Lord; His grace flows in abundance to all who do.
- **Deed**—Action in compassion for others and in obedience to the Lordship of Christ to address whatever is unacceptable to Him in every sphere of life in accordance with His Kingdom of God agenda.
- **Sign**—Evidence in our lives, words , deeds and prayers that Jesus is the Lord who alone is powerful.
- **Intercession**—Expressing total reliance on Jesus without which the other three are largely ineffective.

Each one of us can only do a little. At times it may feel like it is too small to be of use! But Jesus has a very large workforce; thousands upon thousands of servants. Each one has a part to play. He is perfectly capable to weave all these contributions together to bring about the completion of His wholistic Kingdom.

សំណុំឱកឃ្មុំ ១/១ (កក្កដា ២០០០): ៣២-៤២

# ព័ន្ធកិច្ច និង បេសកកម្មគ្រប់ជ្រុងជ្រោយ

ដោយ លោក ប្រ៊ាម ឈើប

*******

ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ (គឺគិតបញ្ចូលទាំងបេសកកម្ម) គឺមានន័យថា ការធ្វើជាអ្នកបំរើដល់អ្នកដទៃ ដែលគិតគូរដល់សេចក្ដីត្រូវការរបស់មនុស្សទាំងស្រុង ហើយនិងគិតគូរដល់ស្ថានភាពរស់នៅទាំងស្រុងរបស់មនុស្សនោះ ។ ចំណុចនិមួយៗខាងក្រោមនេះគឺពិតជាត្រូវសំរាប់មនុស្សគ្រប់រូប នៅក្នុងគ្រប់ប្រទេសនានា ។

- មនុស្សគ្រប់រូបព្រះបានបង្កើតមកក្នុងរូបអង្គរបស់ព្រះជាម្ចាស់ ប៉ុន្តែមនុស្សម្នាក់ៗបានក្លាយទៅជាមនុស្សអាត្មានិយម និង បះបោរទាស់នឹងព្រះ ដោយសារតែអំពើបាបនៅក្នុងចិត្ត ។ មនុស្សម្នាក់ៗជាមនុស្សមានបាប ដែលបានប្រព្រឹត្តទាស់ទទឹងនឹងព្រះជាម្ចាស់ ។
- មនុស្សម្នាក់ៗមានប្រព័ន្ធរស់នៅផ្នែករូបកាយ ផ្នែកបញ្ញា ផ្នែកទំនាក់ទំនង ផ្នែកសង្គម ផ្នែកវិញ្ញាណ ផ្នែកចិត្តសាស្ត្រ ផ្នែកអារម្មណ៍ ផ្នែកសីលធម៌ ផ្នែកឆន្ទៈ និង ផ្នែកទំនៀមទំលាប់រៀងៗខ្លួន ។ ផ្នែកនិមួយៗនៃប្រព័ន្ធនេះ មានឥទ្ធិពលយ៉ាងសំខាន់ចំពោះប្រព័ន្ធដទៃផ្សេងទៀត ។
- មនុស្សម្នាក់ៗរស់នៅក្នុងស្ថានភាពរបស់ទំនៀមទំលាប់ គ្រួសារ នយោបាយ ពួកខាងឯវិញ្ញាណ សង្គមជាតិ បរិយាកាស សិល្បៈ ការកែកំសាន្ត ច្បាប់ ហើយនិង ការអប់រំ ។
- មនុស្សម្នាក់ៗ ព្រះបង្កើតមកតម្រូវឲ្យមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ហើយនិង ម្នាក់ៗមានដំណើរការមិនប្រក្រតី នៅពេលដែលទំនាក់ទំនងជាមួយព្រះជាម្ចាស់ចុះខ្សោយ ឬ មិនមានទំនាក់ទំនងនេះទេ ។

• មនុស្សម្នាក់ៗត្រូវជាប់ទោសដល់ស្លាប់អស់កល្បជានិច្ច ដោយសារអំពើបាបរបស់ខ្លួនបើមិនមានព្រះគុណព្រះជួយគេទេនោះ តែគេអាចចូលរួមជាមួយនឹងព្រះយេស៊ូបានដោយសារជំនឿ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយទទួលស្គាល់នូវសារៈសំខាន់នៃការលើកមកនិយាយ ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិតរស់នៅ បើមនុស្សគ្រប់រូប និង ប្រជាជាតិ មានសុភមង្គលបាននោះ ត្រូវបង្កើនការជួយនោះឲ្យហួសពីភាពសើរៗ ។ ការយល់ដឹងរបស់យើងមិនមែនចាប់អារម្មណ៍ និង មិនចាប់អារម្មណ៍ ចំពោះតែសុខមាលភាពប៉ុណ្ណោះទេ កំណត់ឲ្យឃើញនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូល ត្រឹមត្រូវល្អ នៅក្នុងព្រះគម្ពីរ ។

ទោះជាយ៉ាងណាក៏ដោយ មានហេតុផលផ្សេងៗ ដែលមនុស្សបានលើកឡើងមកនិយាយថា ហេតុអ្វីបានជាព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយល្អត្រឹមត្រូវ ។ មានរបៀបផ្សេងៗគ្នាបីយ៉ាង ។ របៀបទីមួយគឺមិនទាក់ទងលើផ្នែកសីលធម៌ របៀបទីពីរល្អ ប៉ុន្តែមានដែនកំណត់ ហើយនិងទីបីល្អបំផុត ពីព្រោះការផ្ដោតសំខាន់ គឺព្រះគ្រីស្ទ ហើយនិងភាពធំឧត្តមរបស់ព្រះអង្គ ជាជាងការផ្ដោតទៅលើសេចក្ដីត្រូវការរបស់មនុស្ស ។

របៀបទាំងបីនៃព័ន្ធកិច្ចនេះគឺ:

១) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគឺជាមធ្យោបាយមួយរហូតដល់ចុងបំផុត។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគ្មានតម្លៃអ្វីឡើយ លើកលែងតែជាមធ្យោបាយមួយដែលងាយស្រួលចូលទៅដល់មនុស្ស ទើបពេលនោះយើងអាចផ្សាយដំណឹងល្អដល់ពួកគេបាន ។

គំនិតបែបនេះ គឺមើលឃើញអ្វីៗគ្រប់យ៉ាងឯទៀត គ្រាន់តែជាមធ្យោបាយមួយ ដែលធ្វើឲ្យមនុស្សព្រមស្ដាប់ដំណឹងល្អតែប៉ុណ្ណោះ ។ ចំពោះហេតុផលបែបនេះ គឺជាការបោកបញ្ឆោត ដើរខ្សែលើ មិនអាចទទួលយកបាន ផ្ទុយពីព្រះបន្ទូល ហើយនិង មិនបានលើកសរសើរដល់ព្រះជាម្ចាស់ ។

២) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺជាការស្ដែងចេញនៃសេចក្ដីស្រឡាញ់ ហើយនិង ការប្រាថ្នាចង់បានយុត្តិធម៌ និង ភាពសម្បូណ៌សប្បាយនៅក្នុងគ្រប់ផ្នែកនៃជីវិតរស់នៅ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺត្រូវមានការលើកទឹកចិត្ត ដោយការមានបំណងថែទាំដល់មនុស្សម្នាទាំងឡាយ ។ ព័ន្ធកិច្ចនេះបានលើសពីសេចក្ដីត្រូវការរបស់មនុស្ស ហើយនិង ដំណើររឿងទាំងឡាយនៃជីវិតរស់នៅ ដើម្បីឲ្យ

សុខមាលភាពរបស់មនុស្សទាំងឡាយមានភាពប្រសើរឡើង និង មនុស្សទាំងអស់នឹងបានរួចពីបន្ទុកធ្ងន់ ដោយសារតែការធ្លាក់ស្រុតចុះផ្នែកជីវភាពរស់នៅរបស់មនុស្សម្នាក់ៗ ហើយនិងការស្រុតចុះរបស់សង្គម ។ ហេតុផលនេះល្អ ហើយនិង ស្របតាមព្រះគម្ពីរទៀត ប៉ុន្តែវារំលងចំណុចសំខាន់ ដែលផ្តោតទៅលើព្រះរាជបំណងរបស់ព្រះ ដែលបានកត់ទុកនៅក្នុងយុទ្ធសាស្រ្តទី ៣ នៅខាងក្រោមនេះ ។ គំរូនេះ គឺជួយជំរុញឲ្យធ្វើ "អំពើល្អ" ។

ការបង្ហាញបែបនេះ កាលនៅក្នុងសតវត្សរ៍ទី ១ បានសង្កត់ធ្ងន់ទៅលើតម្លៃនៃការរួមបរិច្ចាគជួយទៅដល់សហគមន៍តាមតំបន់ ។ ព័ន្ធកិច្ចនោះអាចជាការងារតូចតាច ដែលជួយដល់អ្នកជិតខាង ឬ ការងារធំដុំដូចជាការផ្តល់ជំនួយសង្គ្រោះជាបន្ទាន់ ឬ ក៏គម្រោងការអភិវឌ្ឍន៍ ដែលផ្តល់ប្រយោជន៍ដល់សហគមន៍ទាំងមូល ។

៣) ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ គឺជាការព្រមចុះចូលចំពោះការសោយរាជ្យរបស់ព្រះគ្រីស្ទ ។ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគឺដោយទទួលស្គាល់ថាក្នុងនាមជាអ្នកបំរើរបស់ព្រះជាម្ចាស់ យើងត្រូវធ្វើអ្វីៗតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ដូចដែលព្រះអង្គបានធ្វើការរស់នៅក្នុងលោកិយនេះដែរ ។ ព្រះជាម្ចាស់ធ្វើការសម្រេចព្រះរាជបំណងរបស់ព្រះអង្គតាមរយៈនេះ ក្រិត្យច្បាប់របស់ព្រះរាជបុត្រារបស់ព្រះអង្គ ព្រះយេស៊ូគ្រីស្ទ ហើយនិង ព្រះរាជបំណងរបស់ព្រះអង្គជាប់ទាក់ទងទៅនឹងការបំផ្លាស់បំប្រែគ្រប់ជ្រុងជ្រោយទាំងអស់នូវជីវិតទាំងឡាយដែលព្រះអង្គបង្កើតមក (លើកលែងតែអ្វីៗខ្លះ ដែលព្រះអង្គត្រូវលុបបំបាត់តាមរយៈការជំនុំជំរះ) ។

ហេតុផលនេះគឺជាសន្ទុះចិត្តដ៏ខ្លាំងក្លា ពីព្រោះតាំងពីចាប់ផ្តើមរហូតចប់ គឺនៅក្នុងព្រះរាជបំណងព្រះហឫទ័យ របស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទ ។ ចំណុចទាំងឡាយដូចតទៅនេះ រៀបរាប់ពីការងារគ្រប់ជ្រុងជ្រោយ របស់ព្រះជាម្ចាស់ ។

### ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយដើមដំបូងបង្អស់

ព្រះជាម្ចាស់ តែងតែគិតពីភាពគ្រប់ជ្រុងជ្រោយ នៅក្នុងកិច្ចការងាររបស់ព្រះអង្គ ។ ស្នាព្រះហស្តរបស់ព្រះអង្គ ដែលបានបង្កើតមកទាំងអស់គឺ គិតបញ្ចូលទាំងគ្រឿងផ្សំនៃជីវិតរស់នៅ ដែលបានបញ្ជាក់ជូនខាងលើ លើកលែងតែអំពើ

បាប ហើយនិងផលវិបាករបស់វា ។ ព្រះអង្គបង្កើតរបស់សព្វសារពើគឺ: ទាំងរបស់មើលឃើញ និង របស់មើលមិនឃើញ ទាំងមនុស្សទាំងសត្វ ទាំងរបស់មានរូបរាងទាំងរបស់ខាងវិញ្ញាណ ទាំងមនុស្សផ្ទាល់ខ្លួនម្នាក់ៗ ទាំងសង្គមដែលមនុស្សត្រូវរស់នៅ ទាំងផែនដី និង ទាំងផ្ទៃមេឃ ទាំងផ្លូវចិត្ត និង ទាំងបញ្ញា ទាំងរបស់ទន់ទាប និង ទាំងអ្នកត្រួតត្រា និង ទាំងអ្នកមានសិទ្ធិអំណាច ។ ព្រះអង្គបង្កើតទាំងប្រុសទាំងស្រី ទាំងលំហអាកាស ទាំងដែនសមុទ្រ រុក្ខជាតិ និង សត្វគ្រប់ប្រភេទ ខ្យល់ និង ទឹក និង ពពក ។ ស្នាព្រះហស្តព្រះអង្គដែលបានបង្កើតមក មានជីវិតរស់នៅ មានដង្ហើម មានការផ្លាស់ប្តូរកិច្ចការផ្នែកសិល្បៈ ។ កិច្ចការច្នៃប្រឌិតដ៏មានសោភ័ណភាពប្រណិតនេះ គឺស្រស់បំព្រងឥតខ្ចោះជារៀងរាល់ថ្ងៃ ហើយនិងទោះជាយ៉ាងណាក៏ដោយ ប្រណីតភាពនេះគឺមានការផ្លាស់ប្តូររាល់ថ្ងៃ តែមិនបាត់បង់នូវភាពល្អឥតខ្ចោះនោះឡើយ ។ ព្រះជាម្ចាស់បានទតឃើញថាគ្រប់ទាំងអស់ល្អប្រពៃហើយ (លោកុប្បត្តិ ១:៣១) ។

តាំងពីនោះមក អំពើរបស់មនុស្ស និង ការបំផ្លាញរបស់អារក្សមានច្រើនតាមដែលអាចធ្វើបាន ប៉ុន្តែទោះបីជាអារក្សបានធ្វើឲ្យខូច និង ទទួលបណ្តាសារបស់ព្រះជាម្ចាស់ នៅក្នុងសេចក្តីជំនុំជំរះ (លោកុប្បត្តិ ៣) ក៏ដោយរបស់សព្វសារពើ នៅតែរក្សាភាពល្អប្រពៃ ដែលព្រះជាម្ចាស់បានបង្កើតមកនោះបានច្រើន។ របស់សព្វសារពើ បង្ហាញពីសិរីល្អរបស់ព្រះជាម្ចាស់ ហើយនិងនិយាយប្រាប់យើងពីព្រះរាជលក្ខណៈសម្បត្តិ និង អំណាចចេស្តារបស់ព្រះអង្គ (ឧទាហរណ៍ ទំនុកតម្កើង ៨, ១៩, ១០៤, ១៤៨) ។

យើងត្រូវអបអរសាទរដល់របស់សព្វសារពើ ដែលបន្តនាំឲ្យព្រះជាម្ចាស់មានសេចក្តីរីករាយ ហើយយើងត្រូវដឹងទៀតថា តើព្រះអង្គមានព្រះហឫទ័យព្រួយប៉ុណ្ណាទៅ នៅពេលដែលស្នាព្រះហស្តរបស់ព្រះអង្គទទួលរងនូវការប្រព្រឹត្តិដោយមិនយកចិត្តទុកដាក់ ។ ព្រះជាម្ចាស់ផ្តល់នូវការទទួលខុសត្រូវផ្នែកចាត់ចែងមើលថែរបស់សព្វសារពើ និង យើងមិនបានធ្វើការនេះសោះឡើយ ។ នៅពេលដែលយើងមិនបានយកចិត្តទុកដាក់ចំពោះការទទួលខុសត្រូវរបស់យើង ដើម្បីចាត់ចែងឲ្យបានល្អនូវរបស់សព្វសារពើទាំងអស់ ដែលព្រះអង្គបានបង្កើតមក យើងបានប្រកាន់យកនូវឥរិយាបថ ដែលព្រះជាម្ចាស់ព្រះអង្គផ្ទាល់មិនទទួលយកបាន ។

**អំពើបាប សង្គម និង របស់សព្វសារពើដែលព្រះបានបង្កើត ។**

នៅក្នុងលោកុប្បត្តិ ៣-១១ យើងបានអានអំពីផលវិបាកទាំងឡាយ នៃអំពើបាបរបស់មនុស្ស ។ ជីវិតទាំងឡាយបាន និង កំពុងជាប់ឥទ្ធិពលរបស់អំពើបាប សូម្បីតែផែនដីផ្ទាល់នេះ ក៏ទទួលរងឥទ្ធិពលរបស់អំពើបាបដែរ ។ សង្គមមនុស្សរីកចំរើនឡើងដោយមានភាពអំនួត អំពើអាក្រក់ និង អំពើពុករលួយ ហើយនិង ពេលនោះ សេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់ក៏ជោរជន់ឡើង ដោយព្រះអង្គលាងផែនដីដោយទឹកជំនន់ និងកំចាត់កំចាយមនុស្សទៅគ្រប់ទីកន្លែង ទៅតាមភាសាផ្សេងៗ ។ សូម្បីតែបងប្អូនក៏បះបោរប្រឆាំងគ្នា ដោយកាប់សម្លាប់គ្នា ។

ទំនាក់ទំនងរវាងអំពើបាប ហើយនិងរបស់របរសព្វសារពើដែលព្រះបានបង្ហាញយ៉ាងច្បាស់ នៅក្នុងការដែលព្រះដាក់បណ្តាសាដល់ផែនដី ហើយនិងការដែលផ្លាស់ប្តូរក្នុងទំនាក់ទំនងនានា ហើយនិងកិច្ចការធំៗ នៅពេលដែលសេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់បានមកដល់ ក្នុងលោកុប្បត្តិ ជំពូក ៣:១៧-១៩ ។ ដូចដែលលោក ប៉ូល ពណ៌នាពីការរំដោះរបស់សព្វសារពើ ពីបណ្តាសា ហើយនិងភាពពុករលួយរបស់អំពើបាប គឺដោយទាក់ទងផ្ទាល់ជាមួយនិង ការរំដោះឲ្យរួចពីអំពើបាប ដែលព្រះជាម្ចាស់បាននាំមកឲ្យបុត្រាបុត្រីរបស់ព្រះអង្គ ។ ព្រះជាម្ចាស់គឺយកព្រះហឫទ័យទុកដាក់គ្រប់ជ្រុងជ្រោយទាំងអស់ ។

លើសពីនេះទៅទៀត យើងធ្លាប់បានអានជាញយៗមកហើយនៅក្នុងក្រិត្យវិន័យរបស់លោកម៉ូសេ នៅក្នុងទំនុកតម្កើង ហើយនិងនៅក្នុងទំនាយរបស់ពួកហោរា ដែលស្តីពីព្រះហឫទ័យរំជួលរបស់ព្រះជាម្ចាស់ចំពោះមនុស្ស ដែលរងគ្រោះដោយសារអំពើបាបគឺៈ ភាពក្រីក្រ ក្មេងកំព្រា ស្ត្រីមេម៉ាយ ជនដែលត្រូវគេសង្កត់សង្កិន ទណ្ឌិត ជនភៀសខ្លួន ។ អំពើបាប ទាក់ទងនឹងការថ្វាយបង្គំរូបព្រះ ភាពអយុត្តិធម៌ អំពើលោភលន់ ហើយនិងភាពអសីលធម៌ ដែលជាលទ្ធផលនាំឲ្យមនុស្សផ្ទាល់ខ្លួនម្នាក់ៗរងទុក្ខលំបាក និង ប្រជាជាតិទាំងឡាយធ្លាក់ក្នុងអំពើព្រៃផ្សៃ ហើយនិង អំពើហិង្សា ។ ផលវិបាកទាំងឡាយរបស់មនុស្សម្នាក់ៗ និង អំពើបាបនៃលោកិយទាំងមូល គឺជាការខ្វល់ខ្វាយរបស់ព្រះអង្គ ។ គ្រប់ផ្នែកទាំងអស់របស់មនុស្សគ្រប់រូប គ្រប់ផ្នែកទាំងអស់របស់សង្គម និង គ្រប់ផ្នែកទាំងអស់របស់សព្វសារពើ គឺខ្វះមិនដល់សិរីល្អរបស់ព្រះជាម្ចាស់ ។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ព្រះតំរិះរបស់ព្រះអង្គបានបង្ហាញឲ្យយើងឃើញច្បាស់ថា ព្រះ

អង្គមានព្រះហឫទ័យទុក្ខព្រួយ ដោយព្រោះអំពើបាប និង ផលវិបាករបស់អំពើបាបនោះ ។ សេចក្ដីរំដួល និង ការក្តួលអាណិតរបស់ព្រះជាម្ចាស់ គឺគ្រប់ជ្រុងជ្រោយឥតខ្ចោះ ដូចដែលសេចក្តីសន្យារបស់ព្រះអង្គទៅនឹងអ្វី ដែលព្រះអង្គនឹងធ្វើ ការជួយសង្គ្រោះដល់លោកិយ ដែលខូចបាក់បែកនេះ ។

**សេចក្តីសន្យារបស់ព្រះជាម្ចាស់**

សូម្បីតែនៅថ្ងៃ ដែលបណ្តាសានៃការជំនុំជំរះរបស់ព្រះជាម្ចាស់បានប្រកាសជាមុនដំបូងក៏ដោយ ព្រះជាម្ចាស់បានបង្ហាញថា សេចក្តីសន្យារបស់ព្រះជាម្ចាស់គឺ ត្រូវផ្តួលរំលំដល់អាណាចក្ររបស់អារក្ស ។ កូនរបស់ស្ត្រីនឹងជាន់ក្បាលសាតាំង (លោកុប្បត្តិ ៣:១៥) ។ ចំពោះ អ័ប្រាហាំ ព្រះជាម្ចាស់សន្យានូវព្រះពរជូនដល់មនុស្សទូទាំងផែនដី ។ ក្រិត្យវិន័យរបស់ លោក ម៉ូសេ សញ្ជឹងគិតដល់សង្គមដែលកោតខ្លាចព្រះ បរិសុទ្ធ មានសេចក្តីអាណិតអាសូរ និង យុត្តិធម៌ ដោយគិតដល់អ្នកទន់ខ្សោយ និង អ្នកដែលងាយនឹងរងគ្រោះជាពិសេស ។ គ្រប់យ៉ាងទាំងអស់នៅក្នុងសង្គមបែបនោះ គឺមានទំនាក់ទំនងស៊ីចង្វាក់គ្នាទាំងអស់ (គឺគិតទាំងផែនដី) មកទល់ពេលនេះគ្រប់យ៉ាងទាំងអស់ គឺស៊ីចង្វាក់គ្នាក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ ។ ក្រិត្យវិន័យនេះ ផ្តល់ឲ្យយើងនូវចំណាប់អារម្មណ៍យ៉ាងច្រើនចំពោះប្រភេទនៃសង្គម ដែលនឹងនាំឲ្យមានព្រះពរធ្លាក់មកលើប្រជាជាតិទាំងអស់ ដែលព្រះជាម្ចាស់បានសន្យាដល់អ័ប្រាហាំ ។

ចំណុចសំខាន់ចំពោះ សេចក្តីសន្យារបស់ព្រះទាំងអស់នេះ គឺជាសេចក្តីសន្យានៃស្តេចគង្វាល ដែលជាពូជពង្សហ្លួងដាវីឌ ហើយនិង ដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ (ទំនុកតម្កើង ២) ហើយនិង ជាកូនមនុស្ស (ដានីយ៉ែល ៧:៩-១៤) ។ ព្រះអង្គជាព្រះមេស្ស៊ី ហើយនិង តាមរយៈនៃការគ្រប់គ្រងរបស់ព្រះអង្គលើប្រជាជាតិទាំងអស់ ដែលថាព្រះជាម្ចាស់នឹងសម្រេចគ្រប់ទាំងសេចក្តីសន្យា ។ ពួកព្យាការី បាននិយាយម្តងហើយម្តងទៀត ពីព្រះមេស្ស៊ី នេះ ។ (ឧទាហរណ៍ អេសាយ ៩:៦-៧, ១១:១-៥, ៣២:១-៥, ៤២:១-៧, ៥២-៥៣, ៦១:១-៩, យេរេមា ២៣:៥-៦, ៣៣:១៥-១៦, អេសេគាល ៣៤:២០-៣១, ៣៧:២៤-២៨, អេម៉ូស ៩:១១-១៥) ។ ព្រះអង្គនឹងជាអ្នកបំរើរបស់ព្រះជាម្ចាស់ ដែលនឹងត្រូវធ្វើជាយញ្ញបូជា ចំពោះអំពើបាប (អេសាយ ៥៣) ។

អេសេគាល និង យេរេមា សន្យាថាព្រះជាម្ចាស់ នឹងសំអាត និង បន្ទន់ចិត្តរបស់មនុស្ស ឲ្យបានបរិសុទ្ធ ដើម្បីឲ្យមនុស្សបែរទៅរកព្រះជាម្ចាស់ ជាជាងប្រឆាំងនឹងព្រះអង្គ ។ អេសាយ យ៉ូអែល និង អេសេគាល បានប្រកាសថា ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ នឹងចាក់មកលើរាស្ត្ររបស់ព្រះអង្គ ដើម្បី នាំមកនូវការផ្លាស់ប្រែ ការប្រោសលោះ កាញែកជាបរិសុទ្ធ ការកែប្រែជាថ្មី ។ អេសាយបានសង្កត់ធ្ងន់លើភាពយុត្តិធម៌ មេត្រីភាព និង សេចក្តីសុចរិត សំរាប់ ប្រជាជាតិទាំងឡាយនៅលើផែនដី ។ សេចក្តីសន្យាខ្លះៗ នៃការអត់ទោសបាប របស់ព្រះជាម្ចាស់ ។ ចំពោះអស់អ្នកដែលរងគ្រោះ ដោយព្រោះអំពើបាបភាគ ច្រើននឹងប្រទះឃើញនូវសេរីភាពរបស់ព្រះជាម្ចាស់ ដែលបានរួចពីភាពក្រីក្រ ហើយនិងរួចពីការដែលគេសង្កត់សង្កិន ។ ប្រជាជាតិនានានឹងឈប់ធ្វើសង្គ្រាម ទាស់ទែងគ្នា ។ សូម្បីតែនៅក្នុងចំណោមសត្វ ក៏គ្មានការទាស់ទែងគ្នាដែរ ។

និយាយឲ្យខ្លីទៅ សេចក្តីសន្យារបស់ព្រះជាម្ចាស់ គឺត្រូវថ្លែងបញ្ជាក់ពី ជីវិតទាំងមូល (គ្រប់ជ្រុងជ្រោយ) ហើយនិងនាំមកនូវការផ្លាស់ប្រែដល់របស់សព្វ សារពើទាំងអស់ ទោះទាំងនៅលើស្ថានសួគ៌ និង លើផែនដី គឺត្រូវស្របនឹង បំណងព្រះហឫទ័យទាំងស្រុងរបស់ព្រះអង្គ ។ សេចក្តីសន្យារបស់អាណាចក្រ នោះគឺទូទៅ គ្រប់ជ្រុងជ្រោយ និង ពេញលេញនៅគ្រប់ផ្នែកទាំងអស់ ។ សេចក្តី សន្យាផ្តល់មត៌កដល់អស់អ្នកណា ដែលមានជំនឿដូចជាអ័ប្រាហាំ គឺផែនដីទាំង មូលនឹងបានផ្លាស់ប្រែស្របតាមព្រះរាជគ្រប់គ្រងរបស់អាណាចក្រព្រះនៅក្នុងព្រះ គ្រីស្ទ ។

**ការយាងមករបស់ព្រះមេស្ស៊ី**

នៅពេលដែលព្រះយេស៊ូចាប់ផ្តើម ព្រះរាជព័ន្ធកិច្ចរបស់ព្រះអង្គ ព្រះ ទ្រង់បានប្រកាសប្រាប់ពីដើមដំបូងនៃការគ្រប់គ្រងរបស់ព្រះមេស្ស៊ី ដែលបាន សម្រេចតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់ ។ មិនថាឡើយការចាប់ផ្តើមនោះវា តូចប៉ុណ្ណានោះឡើយ កិច្ចការងាររបស់អាណាចក្ររបស់ព្រះជាម្ចាស់ បានចាប់ ផ្តើមឡើង ។ ព្រះយេស៊ូ ហើយនិងពួកសាវ័ក គេបានរាយការណ៍មកថា មាន បន្ទូល និង និយាយពីអាណាចក្រព្រះជានិច្ចរហូត គឺជាចំណុចសំខាន់នៃដំណឹង ល្អ ដែលពួកគេបានផ្សាយចេញទៅនោះ ។ តាមរយៈនៃឱកាសសំខាន់ៗ នៃព្រះ ជន្មរបស់ព្រះអង្គ ព្រះយេស៊ូបើកសម្តោធពីសេចក្តីសន្យារបស់អាណាចក្ររបស់

ព្រះជាម្ចាស់ ។ កំណើត និង ពិធីជ្រមុជទឹក ព័ន្ធកិច្ចជាអ្នកបំរើ ការរងឈឺចាប់ និង ការសុគត ការមានព្រះជន្មរស់ឡើងវិញ ហើយនិងការឡើងទៅស្ថានសួគ៌ និង ជាចុងក្រោយ ការចាក់ព្រះវិញ្ញាណនៅបញ្ចទសទិវា (ថ្ងៃទី ៥០) គឺថា: ម្នាក់ៗមានចំណែកក្នុងការចាប់ផ្ដើមនៃការគ្រប់គ្រងរបស់ព្រះគ្រីស្ទ ដោយយកឈើឆ្កាងជាព្រឹត្តិការណ៍សំខាន់ ។ នៅលើឈើឆ្កាង ព្រះយេស៊ូបានបើកឲ្យមានភាពជាទីទុកចិត្តរបស់ព្រះអង្គ ដែលត្រូវបានគេបញ្ជាក់ថាជាអ្នកគ្រប់គ្រងដ៏ធំឧត្ដម លើគ្រប់ប្រជាជាតិ ហើយនិងគ្រប់គ្រងសាតាំង ដែលជាមហាបច្ចាមិត្ររបស់ព្រះជាម្ចាស់។ លើសពីនេះទៅទៀតនោះ នៅលើឈើឆ្កាងព្រះយេស៊ូបានធ្វើឲ្យសម្រេចតាមតម្រូវការដ៏យុត្តិធម៌ របស់ព្រះបិតាចំពោះអំពើបាប ដោយការសុគតជំនួសមនុស្សមានបាបទាំងឡាយ ។ ការអត់ទោសបាបរបស់ព្រះជាម្ចាស់ គឺសំរាប់អស់អ្នកដែលជឿ និង តាមរយៈជំនឿនេះ សេចក្ដីសន្យានៃអាណាចក្រស្ថានសួគ៌ អ្នកទាំងឡាយនោះនឹងចាប់ផ្ដើមទទួលនូវបទពិសោធន៍ក្នុងជីវិតរបស់គេ ។

គ្មានកន្លែងណាមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលព្រះយេស៊ូ ឬ ពួកសាវ័ក មិនបានលើកមកនិយាយពីលក្ខណៈគ្រប់ជ្រុងជ្រោយរបស់ព្រះមេស្ស៊ី ដែលត្រូវយាងមកធ្វើការនេះ ។ តាមពិតព្រះយេស៊ូ បានបង្ហាញយ៉ាងច្បាស់ពីការដែលព្រះអង្គយកព្រះហឫទ័យទុកដាក់ ចំពោះសេចក្ដីត្រូវការទាំងអស់ របស់មនុស្ស ហើយនិង អ្វីៗគ្រប់យ៉ាង ដែលមនុស្សម្នាក់ៗត្រូវការ ដើម្បីរស់នៅ ។ គុណសម្បត្តិតែមួយគត់ គឺថាមានទំហំធំធេង មានន័យថា : គ្មានការបន្ថយចុះនៃកិច្ចការងាររបស់ព្រះមេស្ស៊ីឡើយ ។ ព្រះយេស៊ូមានបន្ទូលថា នគរព្រះចាប់ផ្ដើមឡើងតូចបំផុត ប៉ុន្តែនគរនោះនឹងរីកចំរើនធំឡើងៗ ហើយនិង មានឥទ្ធិពលលើជីវិតកាន់តែច្រើនឡើងៗ ។ តើការរីកចំរើនឡើង ដល់កំរិតណា មុនពេលព្រះយេស៊ូយាងត្រឡប់មកវិញ ដើម្បីបញ្ចប់ការងារនោះ មិនបានចែងប្រាប់ច្បាស់លាស់ឡើយ ។ រឿងប្រៀបប្រដូច ពីស្រូវសាឡី និង ស្រងែ បានបង្ហាញថា អំពើអាក្រក់របស់លោកីយ៍នៅតែបន្តរីកដុះដាល ទោះបីជានគរព្រះកំពុងរីកចំរើនលូតលាស់ក៏ដោយចុះ ។

នៅក្នុងដំណើរយាងមកផែនដីជាលើកទី ១ របស់ព្រះអង្គ ព្រះយេស៊ូបានតាំងរាជ្យទ្រង់ឡើង តាមរបៀបមួយតូច និង បន្ទាបខ្លួនជាទីបំផុត ។ នៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ ព្រះអង្គនឹងយាងមកដោយព្រះតេជៈ សិរីរុង

រឿង និង ព្រះចេស្តា ដែលគ្មានមនុស្សណាម្នាក់ឆ្ងល់ថា តើព្រះអង្គជាអង្គណា នោះឡើយ ។ នៅពេលនោះ ជាពេលវេលានឹងបានសម្រេចគ្រប់យ៉ាងទាំងអស់ ។ ផែនដីទាំងមូល ប្រជាជាតិនានា និង សង្គមទាំងមូល ព្រមទាំងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល នឹងបានផ្លាស់ប្រែ ទៅជាមានភាពល្អឥតខ្ចោះ ដ៏គ្រប់ជ្រុងជ្រោយរបស់ព្រះជាម្ចាស់ ។

វាជាការសំខាន់ណាស់ ដែលថា យើងមិនភ្លេចនូវរឿងដ៏សំខាន់ចាំបាច់មួយនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ គឺជាការជំនុំជំរះ ។ សេចក្តីជំនុំជំរះ ជាចុងក្រោយនោះ នឹងមានទាំងពីរ ទាំងការដាក់ទណ្ឌកម្ម និង ការសំអាតឲ្យបានស្អាត ។ ព្រះជាម្ចាស់នឹងញែក លុបបំបាត់មនុស្សទាំងឡាយណា ដែលដើរតាមព្រះដទៃ ពួកទុកចិត្តលើខ្លួនឯង ពួកថ្វាយបង្គំរូបព្រះ ពួកសាតាំង និង ពួកដទៃទៀត ដែលស្រដៀងគ្នានេះ ។ ព្រះជាម្ចាស់នឹងលុបបំបាត់ នូវរាល់អំពើអាក្រក់ទាំងឡាយ រហូតដល់ចំណុចដែលហួសពីការផ្លាស់ប្រែ ។ ព្រះជាម្ចាស់នឹងលុបបំបាត់នូវពួកវិញ្ញាណអាក្រក់ ដែលមកពីសាតាំងផ្ទាល់ និង បរិវាររបស់វា ។ ការនេះមិនបានបូកបញ្ចូលរបស់គ្រប់យ៉ាង ដែលជារបស់ព្រះជាម្ចាស់ ដែលនឹងត្រូវនូវការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតនោះគឺ អស់អ្នកណាដែលមិនបានធ្វើការល្អសោះ ។

**សេចក្តីថ្លែងការណ៍សំខាន់ខ្លះៗនៅក្នុងគម្ពីរសញ្ញាថ្មី**

នៅក្នុង អេភេសូ លោកប៉ូលសរសេរសង្កត់ធ្ងន់លើ សិទ្ធិអំណាច និង ការគ្រប់គ្រងដ៏ធំឧត្តម របស់ព្រះយេស៊ូលើគ្រប់អំណាចទាំងអស់ដទៃទៀត (១:២០-២៣) ។ គាត់បាននិយាយផងដែរថាព្រះពរនៃស្ថានសួគ៌ ដែលយើងរាល់គ្នាបានទទួលហើយនោះគឺជាការបើកសម្តែង ពីព្រះជាម្ចាស់ ដូចបានបង្ហាញពីព្រះរាជបំណងរបស់ព្រះអង្គនៅក្នុងព្រះគ្រីស្ទ ។ គ្រប់របស់ទាំងអស់ ទាំងនៅលើស្ថានសួគ៌ និង ផែនដី ត្រូវស្ថិតនៅក្រោមការដឹកនាំ និង ការគ្រប់គ្រងរបស់ព្រះគ្រីស្ទ ។ ការគ្រប់គ្រងនេះ ចាប់ផ្តើមឡើងនៅពេល ដែលដល់ពេលវេលារបស់ព្រះមកដល់ គឺថាព្រះគ្រីស្ទគ្រប់គ្រងលើទាំងអស់ ។ មិនគ្រាន់តែជាការគ្រប់គ្រងគ្រប់ជ្រុងជ្រោយប៉ុណ្ណោះទេ គឺជាការគ្រប់គ្រងលើរបស់គ្រប់យ៉ាងទាំងអស់ ទាំងនៅលើស្ថានសួគ៌ និង ផែនដីផង ។

នៅក្នុង ភីលីព ២:៩-១១ លោកប៉ូលពណ៌នា ពីព្រះយេស៊ូថា បានលើកតម្កើងឡើងដោយព្រះជាម្ចាស់ ឲ្យមានអំណាចចេស្តា និង សិទ្ធិអំណាចដ៏ធំឧត្តម។

ស្របតាមសេចក្ដីសន្យានៅក្នុង អេសាយ ៤៥:២២-២៤ គ្រប់ទាំងអស់ ដែលនៅស្ថានសួគ៌ លើផែនដី ហើយនិង ក្រោមផែនដី នឹងត្រូវលុតជង្គង់ចុះ ចំពោះព្រះយេស៊ូ ដោយទទួលស្គាល់ពីភាពជាព្រះរបស់ព្រះអង្គ ។ នេះជាគោលបំណងរបស់ព្រះជាម្ចាស់ ដែលស្ដែងចេញឲ្យឃើញ នៅក្នុងព្រះគ្រីស្ទ ។

កូលុស ១:១៥-២០ គឺជាអត្ថបទគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង បទគម្ពីរនេះ បានចែងថា គ្រប់របស់ទាំងអស់កើតមកដោយសារព្រះជាម្ចាស់ លោកប៉ូលនិយាយពីការបានជានាជាមួយនឹងព្រះឡើងវិញ ដោយសារឈើឆ្កាង ។ ការពិពណ៌នានៃពាក្យ "គ្រប់របស់ទាំងអស់" នៅក្នុងខ ១៦-១៧ គឺមានន័យថាគ្រប់ជ្រុងជ្រោយទាំងអស់ ក្នុងគ្រប់ផ្នែក ។ ការប្រមូលផ្ដុំនៃភាពគ្រប់ជ្រុងជ្រោយនៃ "របស់គ្រប់យ៉ាង"ដែលក្នុងនោះគិតបញ្ចូលទាំងការជានារបស់ព្រះ តាមរយៈព្រះយេស៊ូ។ ព្រះជាម្ចាស់ គឺគាប់ព្រះហឫទ័យនៃការងារគ្រប់ជ្រុងជ្រោយ ! សេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ គឺគ្រប់ជ្រុងជ្រោយ ! សេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ គឺជាការស៊ីចង្វាក់គ្នា និង "របស់សព្វសារពើ" ដែលបានជានានឹងព្រះអង្គផ្ទាល់ ការជានាបែបនោះគឺថា ទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងរបស់គ្រប់យ៉ាងទាំងអស់" គឺបានល្អឥតខ្ចោះ ។ នៅពេលដែល "របស់គ្រប់យ៉ាង" បានផ្សះផ្សាជាមួយព្រះអង្គផ្ទាល់ ដូច្នេះ "របស់គ្រប់យ៉ាង" អាចទទួលនូវបាននូវភាពចុះសំរុងនឹងគ្នាជាមួយនឹងរបស់ផ្សេងៗទៀត ។

រ៉ូម ៨:១៩-២១ ឆ្លុះបញ្ចាំងឲ្យឃើញពីលក្ខណៈ គ្រប់ជ្រុងជ្រោយ ដូចគ្នានេះដែរ ពីការងារនៃការដោះឲ្យរួច មានសេរីភាព របស់ព្រះជាម្ចាស់ ។

ចំណុចសំខាន់ក្នុងការយល់ដឹងពីភាពគ្រប់ជ្រុងជ្រោយ របស់គ្រីស្ទបរិស័ទខ្លះ គឺជាអធិបតេយ្យភាពរបស់ព្រះយេស៊ូគ្រីស្ទ ។ ព្រះអង្គតែមួយគត់ ដែលជាព្រះអម្ចាស់ និង ព្រះមេស្ស៊ី ។ មានតែព្រះអង្គមួយ តែប៉ុណ្ណោះ ដែលគ្រប់គ្រងលើរបស់ទាំងអស់ដោយប្រកបដោយភាពធំឧត្ដម ។ ព្រះរាជបំណងព្រះហឫទ័យរបស់ព្រះអង្គ ត្រូវយកមកអនុវត្តក្នុងគ្រប់ស្ថានភាពនៃជីវិតរស់នៅ ។ ភាពជាព្រះរបស់ព្រះអង្គ ដែលបានគ្រប់គ្រងលើរបស់សព្វសារពើ នាំមកនូវការផ្លាស់ប្រែដែលជាសេចក្ដីសន្យារបស់ព្រះជាម្ចាស់ គឺត្រង់ចំណុច ដែលថាយើងនឹងចាប់ផ្ដើមយល់ពីលក្ខណៈគ្រប់ជ្រុងជ្រោយនៃការងាររបស់យើង ក្នុងនាមយើងជាអ្នកបំរើព្រះអង្គ ។

**តើអ៊ីចឹងយើងនឹងបំរើដោយរបៀបណា** ?

យើងត្រូវតែធ្វើជាអ្នកបំរើរបស់ព្រះគ្រីស្ទ មុនពេលយើងធ្វើការ អ្វីៗទាំងអស់ឯទៀត ។ ការគ្រប់គ្រងរបស់ព្រះអង្គ គឺជាមូលដ្ឋានសំខាន់ សំរាប់ការកំណត់ឲ្យដឹងពីការងាររបស់យើង ។ របៀបវារៈនៃអាណាចក្រគ្រប់ជ្រុងជ្រោយរបស់ព្រះអង្គគឺជារបស់យើង ។ ព្រះអង្គបានត្រាស់ហៅយើងមកឲ្យដើរតាមព្រះអង្គ នៅក្នុងបេសកកម្ម នៃការបំផ្លាស់បំប្រែគ្រប់ជុងជ្រោយ នៃរបស់គ្រប់យ៉ាងទាំងអស់ ។ នេះជាការងាររបស់ព្រះអង្គ ដែលព្រះអង្គធ្វើការតាមរយៈយើង ។

ព័ន្ធកិច្ច/បេសកកម្មគ្រប់ជ្រុងជ្រោយនៅក្នុងព្រះគម្ពីរ មានបួន ផ្នែកគឺ:

- ព្រះបន្ទូល-ការប្រកាសដំណឹងល្អ ប្រាប់ដល់មនុស្សទាំងឡាយ និង ប្រជាជាតិនានា ដើម្បីឲ្យចុះចូលនឹងព្រះគ្រីស្ទជាអម្ចាស់ ព្រះគុណរបស់ព្រះអង្គហូរមកដ៏ពេញបរិបូណ៌ ដល់អស់អ្នកទាំងឡាយណា ដែលបានធ្វើការផ្សាយដំណឹងល្អនេះ ។
- ការប្រព្រឹត្ត-គឺជាសកម្មភាព ដោយមានសេចក្ដីក្ដួលអាណិត ចំពោះមនុស្សដទៃ ហើយនិង បង្ហាញពីការស្ដាប់បង្គាប់ចំពោះភាពជាព្រះរបស់ព្រះគ្រីស្ទ ដោយលើកយកអ្វីៗ ដែលព្រះអង្គមិនអាចទទួលយកបាន មកថ្វាយដល់ព្រះអង្គ នៅក្នុងផ្នែកទាំងអស់នៃជីវិតរស់នៅ ឲ្យស្របជាមួយនឹងផែនការនៃរបៀបវារៈ របស់ព្រះជាម្ចាស់ នៃអាណាចក្ររបស់ព្រះអង្គ ។
- ទីសំគាល់-គឺជាភ័ស្ដុតាងនៅក្នុងជីវិត ពាក្យសំដី សកម្មភាព និង សេចក្ដីអធិស្ឋានរបស់យើង ដែលប្រកាសថា ព្រះយេស៊ូ ជាព្រះម្ចាស់តែមួយអង្គគត់ដែលមានអំណាចចេស្ដាឧត្ដមនោះ ។
- ការទូលអង្វរ-ដែលសម្ដែងពីការទុកចិត្តទាំងស្រុង លើព្រះយេស៊ូ ដោយគ្មានចាត់ទុកផ្នែកទាំង បី ផ្សេងទៀតថា អត់ប្រសិទ្ធិភាពនោះឡើយ ។

យើងម្នាក់ៗអាចធ្វើបាន តែបន្តិចបន្តួចប៉ុណ្ណោះ ។ ជួនកាល វាហាក់ដូចជាតូចពេក ដែលយើងត្រូវយកមកប្រើ ! ប៉ុន្តែ ព្រះយេស៊ូ មានកងកម្លាំងការងារយ៉ាងច្រើនសំបើម គឺមានរាប់ពាន់នាក់នៃអ្នកបំរើរបស់ព្រះអង្គ ។ ម្នាក់ៗមានចំណែករៀងៗខ្លួនក្នុងការធ្វើការងារនោះ ។ ព្រះអង្គមានសមត្ថភាពដ៏ល្អឥតខ្ចោះក្នុងការវេញផ្គុំងជាមួយគ្នា ដើម្បីនាំមកនូវ ការសម្រេចបាននៃអាណាចក្រគ្រប់ជ្រុងជ្រោយរបស់ព្រះអង្គ ។